# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

---

## ក្រសួងអប់រំ យុវជន និងកីឡា

# ការផលិតសម្ភារៈពិសោធ និងវិធីសាស្ត្របង្រៀនពិសោធ

## មុខវិជ្ជា រូបវិទ្យា

ប្រើប្រាស់ថវិការបស់គម្រោងអភិវឌ្ឍន៍
វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ( USESDP )

---

រាជធានីភ្នំពេញ ឆ្នាំ២០២១

# បុព្វកថា

ទស្សនវិស័យនៃការអប់រំសតវត្សរ៍ទី២១ បានកំណត់យកការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល ជាមូលដ្ឋានគន្លឹះក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៣០ និង២០៥០ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឆ្នាំ២០១៨-២០២៣ ដោយផ្តោតលើការកែលម្អវិធីសាស្ត្របង្រៀន និងរៀន ការផលិតសម្ភារឧបទេស សម្ភារៈពិសោធន៍ ការពិសោធ និងសម្ភារៈបណ្ណាល័យ ដើម្បីឆ្ពោះទៅរកគុណភាពអប់រំប្រកបដោយចីរភាពនៅមធ្យមសិក្សាទុតិយភូមិទូទាំងប្រទេសកម្ពុជា។ ការធ្វើពិសោធលើមុខវិជ្ជាវិទ្យាសាស្ត្រ ពិតជាមានអត្ថប្រយោជន៍យ៉ាងច្រើនចំពោះការបង្រៀន និងរៀន ដែលជួយឱ្យសិស្សចេះអភិវឌ្ឍខ្លួនឯង មានជំនាញ កំណត់ទិសដៅចេះរៀបចំផែនការ និងដោះស្រាយបញ្ហា ជំរុញការអភិវឌ្ឍគំនិត បញ្ញា មានជំនឿទុកចិត្តលើចំណេះដែលទទួលបានពីការពិសោធ បង្កើតនូវគំនិតច្នៃប្រឌិតថ្មី បណ្តុះបំណិនវិជ្ជាជីវៈ ចេះអំពីរបៀបសួរសំណួរ គិតស៊ីជម្រៅ ស្រាវជ្រាវ សង្កេត វិភាគ និងយល់ដឹងអំពីពិភពលោកកាន់តែប្រសើរ។

វិទ្យាស្ថានជាតិអប់រំ បានរៀបចំចងក្រងសៀវភៅពិសោធន៍ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិផ្នែកវិទ្យាសាស្ត្រ ដែលខ្លឹមសារសៀវភៅរួមមាន ការរៀបចំសន្លឹកកិច្ចការពិសោធ សម្ភារៈពិសោធន៍ វិធីសាស្ត្របង្រៀនពិសោធន៍ និងការធ្វើពិសោធដាក់ស្តែង។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមទុកថា ឯកសារនេះនឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្តជាពិសេសគ្រូបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិដែលទទួលបានការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ ក្នុងការអនុវត្តពិសោធន៍ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញការអប់រំវិទ្យាសាស្ត្រនៅកម្ពុជា ឱ្យមានការអភិវឌ្ឍដូចបណ្តាប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សដើម្បីឱ្យមានគុណភាព ទាំងផ្នែកចំណេះដឹង បំណិន និងឥរិយាបថ។

ឯកសារបំប៉នផ្នែកពិសោធន៍រូបវិទ្យាត្រូវបានរៀបចំឡើងដើម្បីពង្រឹង ពង្រីក និងលើកកម្ពស់សមត្ថភាពគ្រូក្នុងការបង្ហាត់បង្រៀនសិស្សស្របតាមកម្មវិធីសិក្សានៅមធ្យមសិក្សាបច្ចុប្បន្នក្នុងកម្រិតវិទ្យាល័យ។

ខ្លឹមសារនៅក្នុងសៀវភៅនេះចែកចេញជាបីផ្នែករួមមាន៖

១.ការផលិតសម្ភារឧបទេសគឺសំដៅលើការច្នៃសម្ភារឧបទេសងាយៗ របៀបប្រើប្រាស់សម្ភារពិសោធ។

២.ការសរសេរសន្លឹកកិច្ចការពិសោធគឺសំដៅលើការអនុវត្តវិធីសាស្រ្តបង្រៀនមានដូចជា បង្រៀន និងរៀនបែបបិះរក ការប្រើវិធីវិទ្យាសាស្រ្តជាដើម។

៣.សារៈប្រយោជន៍នៃសម្ភារឧបទ្ទេសដែលជាចំណែកមួយក្នុងការពង្រីកចំណេះដឹងរបស់គ្រូធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពថែមទៀត។

យើងសង្ឃឹមថាសៀវភៅនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់គ្រូបង្រៀនផ្នែករូបវិទ្យា សម្រាប់ជួយសម្រួលដល់គ្រូបង្រៀន ក្នុងការបង្រៀនពិសោធដោយប្រើប្រាស់សន្លឹកកិច្ចការពិសោធ។ វាជាការជំរុញ និងលើកទឹកចិត្តក្នុងការបង្រៀន និងរៀនដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយគុណភាព។

យើងខ្ញុំជឿជាក់ថាឯកសារនេះនឹងមានចំណុចខ្វះចន្លោះដោយជៀសមិនផុតឡើយ។ ខ្ញុំសង្ឃឹមថាលោកគ្រូ អ្នកគ្រូនឹងជួយផ្តល់យោបល់បំពេញបន្ថែម ក្នុងន័យស្ថាបនាដើម្បីកែលម្អឯកសារនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរថែមទៀត។

**គណៈកម្មការនិពន្ធ**

**១. គណៈកម្មការគ្រប់គ្រង**

១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ

៤-លោក **ថៃ ហេង** នាយករងវិទ្យាស្ថានជាតិអប់រំ

**២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រងសៀវភៅ**

១- លោក **ទូច ចន្ទទុំ** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

២- លោក **មូ ចាន់ថា** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៣- លោកស្រី **ខែក សំណាង** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៤- លោក **ស្រ៊ន់ តៃស្រ៊ីម** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៥- លោក **ហោ សុខហេង** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៦- លោក **ហម ចិន្តា** គ្រូឧទ្ទេសរូបវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

**៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ**

១- លោក **ម៉ៅ សារឿន** ប្រធានដេប៉ាម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

២- លោក **ចេង ថុន** អនុប្រធានដេប៉ាម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

៣- លោក **គឹម លាង** អនុប្រធានដេប៉ាម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

# មាតិកា

បុព្វកថា.....i
អារម្ភកថា..... ii
សេចក្តីផ្តើម .....1
មេរៀន ៖ វិធីវិទ្យាសាស្ត្រ.....8
១. ការកំណត់បញ្ហា .....8
២. ការបង្កើតសម្មតិកម្ម.....8
៣. ការធ្វើតេស្តសម្មតិកម្ម ឬការធ្វើពិសោធន៍ .....9
៤. លទ្ធផល .....9
៥. ការវិភាគ និងសន្និដ្ឋាន .....9
៦. ការសរសេរសន្លឹកកិច្ចការពិសោធន៍.....24
៧. វិធីសាស្ត្របង្រៀន និងរៀនពិសោធន៍.....28
៨. សារប្រយោជន៍នៃសម្ភារឧបទេស.....29
ឯកសារយោង.....30

# សេចក្ដីផ្ដើម

ការបង្រៀនជាមាគ៌ាក្នុងការផ្ដល់ចំណេះដឹងដល់សិស្សតាមរយៈការប្រើប្រាស់វិធីសាស្ត្រ យុទ្ធវិធីដើម្បីឱ្យសិស្សមានការអភិវឌ្ឍផ្នែកបញ្ញាស្មារតី និងរាងកាយ។

វិធីបង្រៀនគឺជាល្បិច ឬជាមធ្យោបាយរបស់គ្រូបង្រៀនដែលក្រោមការដឹកនាំរបស់គ្រូបង្រៀន សិស្សទទួលបាននូវចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ ចេះរស់នៅជាមួយគ្នាព្រមទាំងពង្រីកសតិបញ្ញា ស្មារតី ហើយប្រើប្រាស់ចំណេះដឹងទាំងនោះដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើងក្នុងការរស់នៅរាល់ថ្ងៃ។

គោលវិធីនៃការបង្រៀនត្រូវបានស្គាល់ជាទូទៅថាមានពីរធំៗគឺ គោលវិធីគ្រូមជ្ឈមណ្ឌល និងគោលវិធីសិស្សមជ្ឈមណ្ឌល។

គោលវិធីគ្រូមជ្ឈមណ្ឌលគឺគ្រូជាអ្នកធ្វើគំរូ គ្រូពន្យល់ទ្រឹស្ដី ច្បាប់ គោលការណ៍ រូបមន្ត...ដល់សិស្ស ដោយពុំបានទុកពេលវេលាគ្រប់គ្រាន់ឱ្យសិស្សគិតទេ។ ចំណែកសិស្សស្ដាប់ កត់ត្រា និងធ្វើតាមគ្រូ។

គោលវិធីសិស្សមជ្ឈមណ្ឌលគឺសិស្សរៀនតាមបែបសកម្ម គ្រូដាក់សិស្សស្ថិតក្នុងភាពមានការងារធ្វើ សិស្សគិត ត្រិះរិះពិចារណារកឫសគល់នៃហេតុ និងផលដោយមានការគិតកម្រិតខ្ពស់។ សិស្សវិភាគ និងសន្និដ្ឋានពីហេតុផលដែលបណ្ដាលឱ្យអ្នកវិទ្យាសាស្ត្រអាច/មិនអាចបង្កើតទ្រឹស្ដី ច្បាប់ គោលការណ៍...បានយ៉ាងច្បាស់លាស់។

ដើម្បីគាំទ្រគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល គ្រូត្រូវប្រើវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក វិធីវិទ្យាសាស្ត្រ ...។

## ១. គោលបំណង

- ប្រើប្រាស់ឧបករណ៍ក្នុងមន្ទីរពិសោធន៍
- សរសេរសន្លឹកកិច្ចការពិសោធន៍
- ធ្វើពិសោធដោយប្រើសម្ភារជាក់ស្ដែង
- ប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀនពិសោធន៍

## ២. និយមន័យ

សម្ភារឧបទេសជាឧបករណ៍ ឬសម្ភារជាក់ស្ដែងដែលគ្រូត្រូវប្រើប្រាស់សម្រាប់បង្រៀន និងរៀនដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ ហើយងាយយល់។

វាអាចជាសម្ភារងាយរកបាន សម្ភារច្នៃប្រឌិតដូចជា សៀវភៅសិស្ស សៀវភៅគ្រូ រូបភាព រូបថត ប័ណ្ណសំណួរ ឧបករណ៍ពិសោធន៍ សន្លឹកកិច្ចការ ... សម្ភារចាំបាច់ដទៃទៀតសមស្របតាមមេរៀន។

វិធីសាស្ត្របង្រៀននិងរៀនតាមបែបរិះរកៈ តម្រូវឱ្យសិស្សសង្កេត អង្កេត និងវិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ដើម្បីបង្កើតសំណួរ ធ្វើពិសោធ ឬធ្វើការស្រាវជ្រាវដើម្បីឆ្លើយទៅនឹងសំណួររបស់ពួកគេ និងទាញសេចក្ដីសន្និដ្ឋានសមស្របមួយតាមរយៈលទ្ធផលពិសោធន៍ ឬការសិក្សាស្រាវជ្រាវ។ នៅក្នុងដំណើរការនេះ សិស្សនឹងយល់ពីខ្លឹមសារបានស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រយ៉ាងពិតប្រាកដ។

វិធីវិទ្យាសាស្ត្រ៖ វិទ្យាសាស្ត្រជាការសិក្សាស្វែងយល់អំពីបាតុភូត ហេតុការណ៍ ឬព្រឹត្តិការណ៍ផ្សេងៗ ដែលកើតមានឡើងជុំវិញខ្លួនយើង ថាហេតុអ្វីបានជាមានបាតុភូតនោះកើតឡើង ហើយព្យាយាមពន្យល់អំពីបាតុភូតទាំងនោះដើម្បីឱ្យគេបានដឹង បានយល់។ អ្នកដែលព្យាយាមពន្យល់ឱ្យគេបានយល់ពីបាតុភូត ឬហេតុការណ៍ទាំងនោះត្រូវបានគេហៅថា "អ្នកវិទ្យាសាស្ត្រ ឬអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ"។ ក្នុងការស្រាវជ្រាវ អ្នកវិទ្យាសាស្ត្របានប្រើវិធីរួមមួយ ហៅថា វិធីវិទ្យាសាស្ត្រ។

## ៣. ប្រភព

ប្រភពនៃសម្ភារឧបទេសៈ

- អាចរកបាននៅក្នុងបណ្ណាល័យ(ឯកសារពាក់ព័ន្ធ)
- កាសែត ទស្សនាវដ្ដី ឬអត្ថបទផ្សេងៗទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងវិស្វកម្ម (STEM)...
- មាននៅក្នុងមន្ទីរពិសោធន៍(ចំពោះវិទ្យាសាស្ត្រ)
- អាចច្នៃប្រឌិតបានដោយងាយ និងមានតម្លៃសមស្របដោយប្រើប្រាស់សម្ភារងាយៗដែលអាចរកបានជុំវិញខ្លួនយើង
- តាម Website, YouTube ...

## ៤. ការអភិវឌ្ឍសម្ភារឧបទេសបង្រៀន

### ៤.១ សម្ភារឧបទេសបង្រៀន

តើសម្ភារឧបទេសបង្រៀនជាអ្វី?

ដើម្បីឆ្លើយនូវសំណួរនេះ អ្នកត្រូវពិនិត្យមើលបំណកស្រាយខាងក្រោម៖

ក្នុងនាមជាគ្រូបង្រៀនដ៏ល្អម្នាក់ ត្រូវមានសម្ភារឧបទេសបង្រៀនឱ្យបានគ្រប់គ្រាន់ និងត្រូវប្រើប្រាស់វាឱ្យបានញឹកញាប់ក្នុងពេលបង្រៀន។ គ្រូបង្រៀនត្រូវចេះច្នៃប្រឌិត និងផលិតសម្ភារឧបទេសបង្រៀនងាយៗដោយខ្លួនឯង។ មេរៀននេះនឹងបង្ហាញឱ្យអ្នកយល់ច្បាស់ពីសម្ភារឧបទេសបង្រៀន។ ក្រោយពេលបានបញ្ចប់មេរៀនេះ អ្នកអាចមានលទ្ធភាពផលិតសម្ភារឧបទេសងាយៗ និងអភិវឌ្ឍវាដោយខ្លួនឯង ព្រមទាំងប្រើប្រាស់ក្នុងការពិសោធ។

សៀវភៅអត្ថបទ កាសែត ទស្សនាវដ្ដី សន្លឹកកិច្ចកាពិសោធន៍ ឧបករណ៍ពិសោធន៍ សៀវភៅលំហាត់ គំនូរ រូបភាព រូបថត ប្រដាប់ប្រដាក្មេងលេង វិទ្យុ ទូរទស្សន៍ ដ្យាក្រាម CD, VCD, DVD, LCD, Video, OHP, Power Point, Slides, Radio, Cassette Player, Recorder.........សុទ្ធតែជាឧទាហរណ៍នៃសម្ភារឧបទេសបង្រៀន។

ខាងក្រោមនេះជាសម្ភារឧបទេសបង្រៀនជាក់ស្ដែងមួយចំនួនដែលបានប្រើប្រាស់ក្នុងផ្នែកវិទ្យាសាស្ត្រ និងសង្គម៖

- ភូគោលប្រើក្នុងផែនដីវិទ្យា-ភូមិវិទ្យា និងរូបវិទ្យា
- សន្លឹកកិច្ចការពិសោធន៍ផ្នែកវិទ្យាសាស្ត្រគ្រប់កម្រិត( រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា)

- គំរូកាយវិភាគវិទ្យា ជីវវិទ្យា (ការរំលាយអាហារ)
- សៀវភៅអត្ថបទ-សៀវភៅលំហាត់ គ្រប់កម្រិតថ្នាក់
- សៀវភៅពិសោធន៍ផ្នែកវិទ្យាសាស្ត្រគ្រប់កម្រិតថ្នាក់(រូបវិទ្យា, គីមីវិទ្យា និងជីវវិទ្យា)
- វីដេអូបង្ហាញពីពិសោធន៍បង្ហាញ (Demonstrations) ឬពិសោធន៍ស្រាវជ្រាវ(ពិសោធន៍វាស់វែង) រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា។ល។
- វីដេអូបង្ហាញពី Discovery នៃជីវិតមនុស្ស សត្វ រុក្ខជាតិរស់នៅលើផែនដី។ល។
- ពិសោធន៍តាម YouTube ដែលបង្ហាញពីការផលិត ឬដំឡើងឧបករណ៍ពិសោធន៍ និងបង្ហាញពីការធ្វើពិសោធដើម្បីទទួលបានទិន្នន័យ ឬការវាស់វែងទិន្នន័យ...។
- ពិសោធន៍តាម E-Lab ដោយប្រើប្រាស់កុំព្យូទ័រដែលមាន Software Engineering ដំឡើងរួច ដូចជា PHET, Proteus Simulation, Multi-Sim ...។

សម្ភារបង្រៀន គឺជាឧបករណ៍ទាំងឡាយណាដែលគ្រូបានប្រើក្នុងការបង្រៀន ដើម្បីនាំសារ ឬព័ត៌មានពីគ្រូទៅសិស្ស។ តាមរយៈនៃការប្រើប្រាស់សម្ភារៈនេះ គ្រូអាចសម្រេចវត្ថុបំណងនៃមេរៀនដោយជោគជ័យ។

## ៤.២ តួនាទីនៃសម្ភារឧបទេសបង្រៀន

- **សម្ភារឧបទេសបង្រៀនមានតួនាទីដូចតទៅ ៖**

- ធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅបានល្អ បង្កើតរូបារម្មណ៍ បង្កើតគំនិតថ្មី ងាយស្រួលក្នុងការបង្រៀន និងរៀន
- ផ្សារភ្ជាប់ពីទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង
- ធ្វើឱ្យថ្នាក់រៀនមានលក្ខណៈសកម្ម និងមានភាពរស់រវើក (សិស្សបានអនុវត្តជាក់ស្តែងដោយផ្ទាល់ដៃ) សង្កេត វិភាគ និងធ្វើសំយោគដោយខ្លួនគេផ្ទាល់
-ពង្រីក-ពង្រឹងចំណេះដឹង បណ្តុះស្មារតីឱ្យសិស្សចេះស្វែងរក ច្នៃប្រឌិត-ផលិតសម្ភារឧបទេសដោយខ្លួនឯង
- ធ្វើឱ្យរូបីនូវអ្វីដែលអរូបី។

- **ភាពចាំបាច់មួយចំនួននៃសម្ភារឧបទេសបង្រៀន**

- ងាយរក, ងាយផលិត និងមានតម្លៃថោកសមរម្យ
- ទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- មិនមានគ្រោះថ្នាក់ដល់សិស្ស
- មានទំហំសមស្របនឹងចំនួនសិស្សក្នុងថ្នាក់រៀន (សិស្សងាយពិនិត្យ)
- មានភាពសុក្រិត
- ទាក់ទាញអារម្មណ៍សិស្សឱ្យចង់រៀន

- បង្កលក្ខណៈងាយស្រួលដល់សិស្សដើម្បីគិត វិភាគ និងសំយោគ

- ងាយស្រួលដល់គ្រូផ្សេងៗទៀតដើម្បីប្រើប្រាស់ ។

- **សម្ភារឧបទេសបង្រៀនដែលប្រកបដោយប្រសិទ្ធិភាព**

សម្ភារឧបទេសបង្រៀនប្រកបដោយប្រសិទ្ធិភាព គឺជាសម្ភារឧបទេសដែលបង្កើនប្រសិទ្ធិភាពនៃការបង្រៀន និងរៀន។ ដំណើរការ និងសកម្មភាពនៃការអភិវឌ្ឍសម្ភារឧបទេសបង្រៀនអាចផ្តល់ផលប្រយោជន៍ដល់គ្រូបង្រៀនជាច្រើនដូចជា ៖

- លើកកម្ពស់វិធីសាស្ត្របង្រៀនរបស់ខ្លួន
- បង្កើនសមត្ថភាពស្រាវជ្រាវ និងទទួលបានចំណេះដឹងថ្មីៗ
- មានភាពសប្បាយរីករាយនៅពេលដែលទទួលបានជោគជ័យក្នុងការអភិវឌ្ឍសម្ភារឧបទេសបង្រៀន
- ងាយប្រើសម្ភារឧបទេសក្នុងការបង្រៀន
- ធ្វើឱ្យសម្រេចវត្ថុបំណងរបស់មេរៀន
- ត្រូវបានគេចាត់ទុកថាជាគ្រូល្អម្នាក់

- **ចំណាត់ថ្នាក់សម្ភារឧបទេសបង្រៀន**

សម្ភារឧបទេសបង្រៀនត្រូវបានចែកចេញជាពីរផ្នែក ៖

\+ សម្ភារឧបទេសបង្រៀនរួមសម្រាប់គ្រប់មុខវិជ្ជាទាំងអស់

- សម្ភារឧបទេសមូលដ្ឋានដូចជា សៀវភៅសិក្សា ឯកសារបង្រៀន ក្តារខៀនហ្វឺតសរសេរលើក្តារខៀនដីស...
- សម្ភារឧបទេសសម្រាប់មើល ដូចជា រូបភាព តារាង គំនូរ រូបតំណាង OHP ។ល។
- សម្ភារឧបទេសសម្រាប់ស្តាប់ ដូចជា វិទ្យុ ម៉ាញេ MP3 ។ល។
- សម្ភារឧបទេសសម្រាប់ស្តាប់ផង និងមើលផង ដូចជា វីដេអូ ទូរទស្សន៍ VCD, DVD, LCD, YouTube...
- សម្ភារឧបទេសសម្រាប់ស្តាប់ផង និយាយផងសរសេរផង និងមើលផង ដូចជា Facebook, Telegram, Messenger, Skype...
- សម្ភារឧបទេសទំនើប ដូចជា Computer, smart phone, Internet, ... ។

សម្គាល់៖ YouTube, Facebook, Telegram, Messenger, Skype... ប្រើលើបណ្តាញអ៊ីនធឺណិត។

\+ សម្ភារឧបទេសបង្រៀនសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ

- ឧបករណ៍ពិសោធន៍ ( Equipment or Apparatus )
- សន្លឹកកិច្ចការពិសោធន៍ ( Worksheet of experiments )
- ម៉ូដែល ( Models )
- រូបកាយវិភាគវិទ្យា ( Anatomy )

- ដើម្បីបង្ហាញបាតុភូតតូច
- ដើម្បីបង្ហាញបាតុភូតធំៗ
- ដើម្បីប្រឌិតធម្មជាតិសិប្បនិម្មិត
- ដើម្បីបង្ហាញខ្លួនមនុស្ស។

## ៥. ផែនការអភិវឌ្ឍសម្ភារឧបទេសបង្រៀន

### ៥.១ ចំពោះសម្ភារឧបទេសបង្រៀនជា Model

គ្រូបង្រៀនអាចអភិវឌ្ឍសម្ភារឧបទេសបង្រៀនតាមជំហានដូចខាងក្រោម ៖

(ក) ធ្វើផែនការការងារ

ចំណុចនេះត្រូវគិតពីដំណាក់កាលដូចខាងក្រោម៖

វត្ថុបំណងមេរៀន៖ ត្រូវរកមើលសម្ភារ (Materials)/ឧបករណ៍(Tools)ដែលមាន និងគិតពីរបៀបបង្កើតវា។

(ខ) ផលិតសម្ភារឧបទេសបង្រៀន។ ចំណុចនេះពាក់ព័ន្ធនឹងការងារក្នុងរោងជាង។

(គ) ប្រើប្រាស់សម្ភារឧបទេសបង្រៀនទាំងអស់នេះនៅក្នុងថ្នាក់រៀនជាក់ស្តែង។

(ឃ) វាយតម្លៃសម្ភារឧបទេសទាំងនេះតាមរយៈមិត្តភក្តិ គ្រូបង្រៀនដទៃទៀត និងព័ត៌មានត្រឡប់ពីសិស្ស។

(ង) កែលម្អសម្ភារឧបទេសទាំងនេះឡើងវិញ។

យើងនិយាយឡើងវិញពីការធ្វើផែនការអភិវឌ្ឍសម្ភារឧទេសបង្រៀន។ ផែនការនេះអាចត្រូវបានធ្វើដោយខ្លួនឯង ឬតាមរយៈការផ្លាស់ប្តូរយោបល់ជាមួយសហសេវិករបស់ខ្លួន។ អ្នកត្រូវសរសេរលើក្រដាសផែនការសាកល្បងនូវ ៖

- ឈ្មោះសម្ភារឧបទេស(Model)/ ឈ្មោះផលិតផល
- សម្ភារឧបទេស(Model)/ ផលិតផលប្រើប្រាស់ក្នុងមេរៀនណាមួយ
- វត្ថុបំណងនៃការផលិតសម្ភារឧបទេសបង្រៀន (Model)
- តម្រូវការសម្ភារឧបទេស
- ពណ៌នាពីដំណើរការផលិត ឬបង្កើតវា ប្រសិនបើចាំបាច់ពណ៌នាពីរបៀបប្រើប្រាស់វា និងបង្ហាញលទ្ធផល
- គូររូបតាងផលិតផលចុងក្រោយ
- កម្មវិធីស្រាវជ្រាវ
- លទ្ធផល និងសន្និដ្ឋាន។

#### ៥.១.១ ឧទាហរណ៍នៃផែនការសាកល្បង

១. ឈ្មោះផលិតផល (Name of Product)

ឧបករណ៍វាស់ពេលប្រតិកម្ម / ល្បឿនសរសៃប្រសាទ របស់មនុស្ស

២. សម្ភារឧបទេស (Model)/ ផលិតផលប្រើប្រាស់ក្នុងមេរៀន (Use in Topics) ទន្លាក់សេរី (reaction time) អនុវត្តក្នុងមេរៀន ប្រព័ន្ធសរសៃប្រសាទ ជីវវិទ្យា ថ្នាក់ទី១១

៣. វត្ថុបំណងនៃការផលិតសម្ភារឧបទេសបង្រៀន (Objectives) សិស្សអាចវាស់ពេលប្រតិកម្ម ឬរផ្លិច (Reflection) ឬល្បឿនសរសៃប្រសាទរបស់មនុស្សម្នាក់ៗបានត្រឹមត្រូវ។

៤. តម្រូវការសម្ភារឧបទេស (Material require) ក្រដាសកាតុង ខ្មៅដៃ ឬ ប៊ិច កន្ត្រៃ និងបន្ទាត់ (អ្នកអាចប្រើតែបន្ទាត់មួយជំនួសក៏បាន)

៥. ដំណើរការផលិត (Procedure)

៥.១ ការផលិត / ការដំឡើង (Set up)

ក. កាត់ក្រដាសកាតុងរាងជាចតុកោណកែងដែលមានទទឹងប្រហែលជា 4.0 cm និងបណ្ដោយប្រហែលជា 30 cm ដោយប្រើកន្ត្រៃ។

ខ. គ្រិតជាសង់ទីម៉ែត្រលើក្រដាសកាតុងមានរាងជាចតុកោណកែងដោយប្រើបន្ទាត់និងខ្មៅដៃ។

៥.២ របៀបប្រើ / ដំណើរការពិសោធន៍ (How to use)

ក. សិស្សម្នាក់(ទី១)ឈរកាន់ក្រដាសកាតុង(បន្ទាត់)ដែលគ្រិតរួចដូចបង្ហាញក្នុងចំណុច(ខ) ត្រង់ចុងម្ខាង ដោយលៃយ៉ាងណាឱ្យក្រដាសកាតុង(បន្ទាត់)សន្ធឹងត្រង់ចុះក្រោម។

ខ. សិស្សម្នាក់ទៀត (ទី២) អង្គុយសន្ធឹងដៃម្ខាងចាំចាប់ក្រដាសកាតុង(បន្ទាត់)ដែលធ្លាក់ឆ្លងកាត់បង្ហារវាងមេដៃ និងម្រាមដៃបង្ហាញដូចរូបខាងក្រោម។

គ. សិស្សទី១ទម្លាក់ក្រដាសកាតុង(បន្ទាត់)ឱ្យឆ្លងកាត់ជំពាមដៃរបស់សិស្សទី២ និងសិស្សទីពីរពិនិត្យមើល រួចចាប់ក្រដាសកាតុង(បន្ទាត់)នេះ។

ឃ. អានតម្លៃលើក្រដាសកាតុង(បន្ទាត់)ដែលចាប់បាន រួចកត់ត្រាក្នុងតារាងលទ្ធផលខាងក្រោម។

ឆ. ធ្វើចំណុច គ. និង ឃ. នេះសារឡើងវិញយ៉ាងហោចណាស់ឱ្យបាន៥ដង។

៦. រូបតំណាងផលិតផល



(ដៃសិស្សទី១អ្នកកាន់បន្ទាត់រួចទម្លាក់)

(ដៃសិស្សទី២អ្នកចាប់បន្ទាត់ដែលធ្លាក់)

៧. ដំណាក់កាលស្រាវជ្រាវ

- ស្រាវជ្រាវតាមរយៈសៀវភៅសិក្សា
- តាមរយៈចូលក្នុងបណ្ណាល័យ
- អ៊ីនធឺណិត (Internet)...

- ប្រមូលសម្ភារ និង Tools ព្រមទាំងផលិតគំរូសាកល្បង
- សរសេរសន្លឹកកិច្ចការ
- ត្រៀមខ្លួនដើម្បីបង្រៀននៅក្នុងថ្នាក់ជាក់ស្តែង។

៨. លទ្ធផល (Result)

| ពិសោធលើកទី | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| កម្ពស់ $h$ (m) | | | | | |
| រយៈពេល $t$ (s) | | | | | |
| រយៈពេល(ពេលប្រតិកម្ម) | $\bar{t} = \frac{t_1 + t_2 + t_3 + t_4 + t_5}{5}$ | | | | |

❖ ការគណនាគំរូ

$$h = \frac{1}{2}gt^2, \qquad t = \sqrt{\frac{2h}{g}}$$

៩. សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ ពេលប្រតិកម្ម ឬរេផ្លិច (Reflection) ឬល្បឿនសរសៃប្រសាទរបស់សិស្សទី២មានរយៈពេល $\bar{t}$=……………។ ដូចនេះដោយប្រើសម្ភារឧបទេសនេះ យើងអាចវាស់ពេលប្រតិកម្ម, រេផ្លិច (Reflection) ឬល្បឿនសរសៃប្រសាទរបស់មនុស្សយើងម្នាក់ៗបានត្រឹមត្រូវ។

# មេរៀន ៖ វិធីវិទ្យាសាស្ត្រ

វិធីវិទ្យាសាស្ត្រមាន៥ជំហានគឺ៖ ការកំណត់បញ្ហា ការបង្កើតសម្មតិកម្ម ការធ្វើតេស្តសម្មតិកម្ម ឬការធ្វើពិសោធន៍លទ្ធផល ការវិភាគ និងការសន្និដ្ឋាន។

## ១. ការកំណត់បញ្ហា

ការកំណត់បញ្ហាចាប់ផ្តើមចេញពីចំណាប់អារម្មណ៍ទៅលើបាតុភូត ឬព្រឹត្តិការណ៍ណាមួយដែលកើតមានឡើងជុំវិញខ្លួនយើង តាមរយៈការសង្កេតរបស់យើង។ ខាងក្រោមនេះជាឧទាហរណ៍ងាយៗដែលបង្ហាញពីបាតុភូតមួយចំនួនទាក់ទងទៅនឹងមុខវិជ្ជាវិទ្យាសាស្ត្រ។



1. សត្វល្អិតចូលចិត្តចោមរោមផ្កាពណ៌លឿង។




2. តើកត្តាអ្វីខ្លះដែលជំរុញឱ្យដែកឡើងច្រែះ?



3. តើឥន្ទធនូបង្កើតឡើងយ៉ាងដូចម្តេច?

ដូចនេះ ការកំណត់បញ្ហាជា ការបង្កើត"សំណួរ " ដែលកើតចេញពីចម្ងល់របស់យើងតាមរយៈការសង្កេតបាតុភូត ឬហេតុការណ៍ណាមួយដែលបានកើតមានឡើង។

## ២. ការបង្កើតសម្មតិកម្ម

សម្មតិកម្មមានន័យថា លទ្ធផលសង្ឃឹមទុកជាមុនដែលនឹងអាចកើតមានឡើង។ ដូច្នេះការបង្កើតសម្មតិកម្មជា ការព្យាករណ៍ ឬការទាយទុកជាមុនដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាដែលយើងបានចោទសួរពីខាងដើម ។ សម្មតិកម្មដែលបង្កើតហើយនេះ ត្រូវមានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវហើយគេអាចយកទៅធ្វើតេស្តសម្មតិកម្មបាន។

ឧទាហរណ៍៖ប្រសិនបើយើងជ្រើសរើសផ្កាពណ៌លឿងតើវាជាផ្កាស្បៃរឿង ផ្កានទោងឬជារុក្ខជាតិអ្វី?ប្រសិនបើយើងជ្រើសរើសដែកគោល ដែកថែប ដែកសួស កម្មដែលយើងបង្កើតមានច្រើនបែបសណ្ឋានណាស់អាស្រ័យនឹងផលដែលយើងរំពឹងទុក។ ខាងក្រោមនេះជាសម្មតិកម្មដែលយើងលើកឡើង៖

ឧទាហរណ៍១ " ផ្កាស្បៃរឿង និងផ្កានទោងពណ៌លឿងទាក់ទាញមេអំបៅ "

ឧទាហរណ៍២ " ទឹកអំបិលអាចជាកត្តាដែលជំរុញឲ្យដែកឡើងច្រែះ "

ឧទាហរណ៍៣ "ពន្លឺព្រះអាទិត្យឆ្លងកាត់តំណក់ទឹក ភ្លៀងរលឹមបង្កើតឥន្ទធនូនៅលើផ្ទាំងជុំពពកឬលើភ្នំ"

## ៣. ការធ្វើតេស្តសម្មតិកម្ម ឬការធ្វើពិសោធន៍

តេស្តសម្មតិកម្មគឺជាការធ្វើពិសោធជាក់ស្តែង ដើម្បីផ្ទៀងផ្ទាត់ថាតើអ្វីដែលយើងបានព្យាករណ៍ទុកជាមុននោះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមសម្មតិកម្ម។ ម៉្យាងទៀតការពិសោធត្រូវមានបទដ្ឋានការងារច្បាស់លាស់ រួមមានសម្ភារពិសោធន៍ ដំណើរការពិសោធន៍ និងពិសោធន៍ត្រួតពិនិត្យ ឬពិសោធន៍ប្រៀបធៀប។

ឧទាហរណ៍ទី1






ឧទាហរណ៍ទី3



ប្រើបាញ់ទឹក ឬព្រួសទឹកចេញពីមាត់ឱ្យឆ្លងកាត់ពន្លឺបង្កើតឥន្ទធនូ

នៅក្នុងការពិសោធវាមានកត្តា និងផលប៉ះពាល់ជាច្រើន ដែលធ្វើឲ្យដំណើរការពិសោធន៍របស់យើងមានភាពប្រែប្រួល។ ដូចនេះមុននឹងពិសោធយើងត្រូវពិនិត្យលក្ខខណ្ឌឲ្យបានច្បាស់លាស់ជាមុនសិន ។

## ៤. លទ្ធផល

លទ្ធផលជាទិន្នន័យដែលទទួលបានពីការពិសោធនតាមរយៈការសង្កេត និងការវាស់វែងយ៉ាងត្រឹមត្រូវ។ ទិន្នន័យនេះចែកចេញជាពីរផ្នែក៖

ទិន្នន័យផ្នែកបរិមាណ៖ ជាទិន្នន័យដែលយើងអាចវាស់វែងបានច្បាស់លាស់ដូចជា ប្រវែង ម៉ាសមាឌ រយៈពេល សីតុណ្ហភាព តង់ស្យុង...

ទិន្នន័យផ្នែកគុណភាព៖ ជាទិន្នន័យដែលយើងពិបាកក្នុងការវាស់វែងឱ្យបានច្បាស់លាស់មានដូចជា ក្លិន ពណ៌ រសជាតិ រូបភាព សូរ...។

ចំពោះឧទាហរណ៍ទី២៖ ក្រោយពីទុកវាអស់រយៈពេលពីរសប្តាហ៍មក គេទទួលបានលទ្ធផលដូចតទៅ៖ ដែកគោលដែលគេដាក់ក្នុងសូលុយស្យុងអំបិលមានពណ៌ត្នោតជាង។ នេះមានន័យថា វាឡើងច្រែះជាងដែកគោលក្នុងទឹកធម្មតា។

## ៥. ការវិភាគ និងសន្និដ្ឋាន

### ៥.១.ការវិភាគ

ការវិភាគទិន្នន័យមានន័យថា"**ទិន្នន័យដែលទទួលបាននោះគាំទ្រ ឬមិនគាំទ្រសម្មតិកម្ម**" ដែលយើងបានបង្កើត ។ ប៉ុន្តែលទ្ធផលនៅក្នុងឧទាហរណ៍ទី២នោះ គឺបានគាំទ្រសម្មតិកម្ម ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ៖ "**ទឹកអំបិលអាចជំរុញឲ្យមានការឡើងច្រែះ**" ត្រូវបានគាំទ្រដោយពិសោធ។ ករណីនេះ *ហាក់ដូចជា*ថា **កត្តាមួយក្នុងចំណោមកត្តាដែលជំរុញឲ្យមានការឡើងច្រែះគឺទឹកអំបិល។** យើងប្រើពាក្យ ***ហាក់ដូចជា*** នេះ ព្រោះយើងធ្វើការពិសោធបានតែម្តង ។ យើងមិនអាចសន្និដ្ឋានថាការពិសោធនោះត្រឹមត្រូវ១០០%នោះទេ។ ប្រសិនបើយើងធ្វើការពិសោធច្រើនដងសារចុះសារឡើង ហើយលទ្ធផលនៃការពិសោធនោះបានគាំទ្រសម្មតិ

កម្មគ្រប់ករណី។ ពេលនោះសម្មតិកម្មរបស់យើង នឹងក្លាតជាទ្រឹស្ដី។ ដូច្នេះ**ទ្រឹស្ដី**មានន័យថា " **ជាការពន្យល់អំពីបាតុភូត ឬព្រឹត្តិការណ៍ផ្សេងៗជាច្រើនដែលត្រូវបានគាំទ្រដោយពិសោធ**"។

ដូច្នេះទ្រឹស្ដីគឺជាសម្មតិកម្ម ឬការប៉ាន់ស្មានដោយមានហេតុផលអំពីអ្វីមួយដែលកើតពីអារម្មណ៍ ឬការគិតរបស់អ្នកវិទ្យាសាស្ត្រ ហើយជួនកាលអាចធ្វើពិសោធន៍បាន ឬធ្វើពិសោធន៍មិនបាន។ ទ្រឹស្ដីដែលមិនអាចធ្វើពិសោធន៍បានរួមមាន ទ្រឹស្ដីអាតូម ទ្រឹស្ដីធៀបរបស់លោកអាំងស្តាំង ទ្រឹស្ដីអេឡិចត្រូម៉ាញេទិចនៃពន្លឺ ។

ក្នុងករណីខ្លះទ្រឹស្ដីថ្មីដែលទទួលយកបានដោយអ្នកវិទ្យាសាស្ត្រ គឺដោយសារតែសម្មតិកម្មតាមបែបបរិមាណប្រសើរជាងទ្រឹស្ដីចាស់ និងក្នុងករណីជាច្រើន គឺថាទ្រឹស្ដីថ្មីពន្យល់បាតុភូត(គាំទ្រដោយពិសោធន៍) បានទូលាយជាងទ្រឹស្ដីចាស់ ដូចជាទ្រឹស្ដីធៀបរបស់អាំងស្តាំង។

ដ្យាក្រាមខាងក្រោមនេះ បង្ហាញអំពីជំហានទាំងប្រាំនៃវិធីវិទ្យាសាស្ត្រដែលអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវបានអនុវត្តក្នុងការធ្វើពិសោធជាច្រើនដង ឬច្រើនលើកច្រើនសារ (ហើយលទ្ធផលសុទ្ធតែបានគាំទ្រដោយពិសោធន៍)ដើម្បីបង្កើតទ្រឹស្ដីមួយដែលមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ ។




មានន័យថា៖

១. ការពន្យល់អំពីអ្វីមួយដែលកំណត់ថានឹងកើតមានឡើងនៅជុំវិញខ្លួនយើង។

២. ការពន្យល់ទៅលើបាតុភូត ឬព្រឹត្តិការណ៍ផ្សេងៗដែលត្រូវបានគាំទ្រដោយពិសោធន៍។

## ៥.២ ចំពោះសម្ភារឧបទេសបង្រៀនជា សន្លឹកកិច្ចការពិសោធន៍

### ៥.២.១ សន្លឹកកិច្ចការពិសោធន៍ជាពិសោធបង្ហាញ (Worksheet of Demonstration)

ចំពោះផែនការនៃការអភិវឌ្ឍសន្លឹកកិច្ចការគឺមានលក្ខណៈដូចគ្នានឹងការផលិតសន្លឹកកិច្ចការ ផ្នែកម៉ូដែល (Model) ខាងលើ។ យើងមិនអាចធ្វើពិសោធន៍ដោយគ្មានសន្លឹកកិច្ចការពិសោធន៍បានទេ។ សន្លឹកកិច្ចការពិសោធន៍ជាសម្ភារឧបទេសមួយដ៏សំខាន់សម្រាប់គ្រូបង្រៀន និងសិស្ស។ វាអាចត្រូវបានចែកជាពីរគឺសន្លឹកកិច្ចការពិសោធន៍បង្ហាញ (Demonstrations) និងសន្លឹកកិច្ចការពិសោធន៍ស្រាវជ្រាវឬវាស់វែង (Experiments)។ សន្លឹកកិច្ចការពិសោធន៍មានច្រើនបែប ច្រើនយ៉ាង ខ្លះវែង ខ្លះខ្លីទៅតាមការផលិត ឬសរសេររបស់អ្នកនិពន្ធ។ អ្នកនិពន្ធខ្លះយល់ថា ការសរសេរសង្ខេបខ្លីគឺធ្វើឱ្យសិស្សងាយយល់ខ្លឹមសារមេរៀនជាងការសរសេរវែងព្រោះសិស្សងាយចងចាំ តែអ្នកនិពន្ធខ្លះទៀតយល់ថាការសរសេរវែងងាយស្រួលជាងការសរសេរសង្ខេបខ្លី ព្រោះវាបង្ហាញពីលំដាប់លំដោយ និងទំនាក់ទំនងស៊ីសង្វាក់គ្នាពីមួយទៅមួយយ៉ាងពេញលេញដែលធ្វើឱ្យសិស្សមិនពិបាកគិត និងងាយយល់។ យើងនឹងសិក្សាសន្លឹកកិច្ចការពិសោធន៍បង្ហាញនៅផ្នែកនេះ។ ខាងក្រោមនេះជាគំរូមួយនៃការសរសេរសន្លឹកកិច្ចការ។

នៅពេលអ្នកសរសេរសន្លឹកកិច្ចការ អ្នកត្រូវគិតអំពី៖

១. វត្ថុបំណង

២. ទ្រឹស្តី ( ជួនកាលអាចសរសេរសង្ខេបៗ ឬរូបមន្តដែលប្រើក្នុងពិសោធន៍)

៣. តម្រូវការសម្ភារឧបទេស

៤. វិធីបង្រៀន

យើងប្រើវិធីសាស្ត្របង្រៀនតាមបែបវិធីវិទ្យាសាស្ត្រ

ការកំណត់បញ្ហា

ការបង្កើតសម្មតិកម្ម

ការធ្វើតេស្តសម្មតិកម្ម ឬធ្វើពិសោធន៍

លទ្ធផល

ការវិភាគ និងទាញសេចក្តីសន្និដ្ឋាន។

៥. សំណួរពិភាក្សា

ឧទាហរណ៍ គំរូសន្លឹកកិច្ចការពិសោធបង្ហាញ

**អត្ថិភាពសម្ពាធបរិកាស**

(ជំពូកទី១ មេរៀនទី៤ ថ្នាក់ទី១០ បោះពុម្ពឆ្នាំ ២០០៧)

១. វត្ថុបំណង

សិស្សបង្ហាញបានពីអត្ថិភាពនៃសម្ពាធបរិយាកាសទៅលើវត្ថុផ្សេងបានយ៉ាងត្រឹមត្រូវ។

២. ទ្រឹស្តី ឬចំណេះដឹងមូលដ្ឋាន

សម្ពាធបរិយាកាសមានតម្លៃធំសម្បើមណាស់។ គេមិនអាចដឹងបានយ៉ាងជាក់ស្តែងទេ ព្រោះថាវត្ថុមួយដែលស្ថិតក្នុងខ្យល់ត្រូវតែទទួលរងនូវកម្លាំងសង្កត់ពីគ្រប់ទិសទី។ គេប្រមាណឃើញថា តួខ្លួនមនុស្សម្នាក់ដែលមានផ្ទៃប្រហែល 1.5 $m^2$ រងនូវកម្លាំងសង្កត់របស់បរិយាកាសប្រហែល $15x10^4$ N ដោយយើងមិនបានដឹងខ្លួនថាយើងរងនូវកម្លាំងនេះផង។ នេះដោយសារតែកម្លាំងខ្យល់ដែលនៅក្នុងខ្លួនមនុស្ស ឬរាងកាយយើងទប់ទល់នឹងកម្លាំងសង្កត់របស់ខ្យល់ពីក្រៅ។ សម្ពាធបរិយាកាសគឺបានដោយសារការសង្កត់ (ទម្ងន់ខ្យល់)របស់ខ្យល់មកលើយើង។

សម្ពាធបរិយាកាសមានតម្លៃ $P_{atm} = 1.013 \times 10^5 \text{Pa}$ ឬ $P_{atm} = 1.013 \times 10^5 \text{ N/m}^2$ ។

- រូបមន្តសម្ពាធ $P = \frac{F}{A}$

ដែល $P$សម្ពាធ គិតជាប៉ាស្កាល់(Pa), $F$កម្លាំងសង្កត់ឬកម្លាំងកែងគិតជាញូតុន(N), $A$ផ្ទៃរងសម្ពាធគិតជា ($m^2$)

- រូបមន្តទម្ងន់ ឬកម្លាំងទំនាញផែនដី $W = mg$

ដែល $W$ទម្ងន់គិតជាញូតុន(N), $m$ម៉ាសរបស់អង្គធាតុគិតជាគីឡូក្រាម(kg), $g$ សំទុះទំនាញដីគិតជា($m/s^2$) ឬ (N/kg)។

៣. តម្រូវការសម្ភារៈ

កែវទឹក១, ក្រដាសកាតុងមានទំហំធំជាងមាត់កែវបន្តិច១សន្លឹក, ទឹកផឹក១ដប

៤. វិធីសាស្ត្របង្រៀន

ការកំណត់បញ្ហា

តើមានអ្វីកើតឡើងចំពោះទឹកនៅក្នុងកែវ និងក្រដាសកាតុង ពេលយើងផ្កាប់មាត់កែវចុះក្រោម?

ក. ទឹក និងក្រដាសកាតុងធ្លាក់ចុះក្រោម។

ខ. ទឹក និងក្រដាសកាតុងមិនធ្លាក់ចុះក្រោម។

គ. គំនិតផ្សេងៗ។




ហេតុអ្វីបានជាអ្នកគិតដូច្នេះ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………។

ការបង្កើតសម្មតិកម្ម

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………។

ការធ្វើតេស្តសម្មតិកម្ម ឬធ្វើពិសោធន៍

- ដំណើរការ (ការដំណើង និងរបៀបប្រើ)

ក.ចាក់ទឹកចូលក្នុងកែវរហូតដល់ជិតពេញ ឬពេញកែវ

ខ. យកក្រដាសកាតុងគ្របមាត់កែវ រួចបាតដៃស្តាំសង្កត់លើក្រដាសកាតុងផ្ទប់មាត់កែវ និងដៃឆ្វេងកាន់គូទកែវ

គ. បង្វិលកែវស្របនឹងរង្វិលទ្រនិចនាឡិកាដើម្បីបានគូទកែវឡើងលើ និងមាត់កែវចុះក្រោម

ឃ. ដកបាតដៃស្តាំចេញពីមាត់កែវឬក្រដាសកាតុងថ្នមៗតែដៃឆ្វេងកាន់គូទកែវដដែល (ដៃស្តាំ)

ង. សង្កេតមើលទឹក-ក្រដាសកាតុងដូចបង្ហាញក្នុងរូបខាងក្រោម។ តើមានអ្វីកើតឡើង?

លទ្ធផល (Result)

ក.ទឹក និងក្រដាសកាតុងធ្លាក់ចុះក្រោម

ខ.ទឹក និងក្រដាសកាតុងមិនធ្លាក់ចុះក្រោម

គ. គំនិតផ្សេងៗ

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

……………………………………………………………………………………………។

ការវិភាគ និងទាញសេចក្តីសន្និដ្ឋាន

- ប្រៀបធៀបលទ្ធផលដែលទទួលបានតាមរយៈពិសោធន៍ទៅនឹងចម្លើយ ឬសម្មតិកម្មរបស់អ្នកថាតើសម្មតិកម្មត្រូវបាន (គាំទ្រ / មិនគាំទ្រ )ដោយពិសោធន៍។

៥. សំណួរពិភាក្សា

(ក) តើសម្ពាធបរិយាកាសសង្កត់លើផ្ទៃទឹកធ្វើឱ្យទឹកលូតតាមបំពង់ទុយោតូចមួយដែលផ្នែកខាងលើរបស់វាមានលក្ខណៈសុញ្ញាកាសបានកម្ពស់ប៉ុន្មា? ចូរបង្ហាញការគណនារបស់អ្នក។

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

……………………………………………………………………………………………។

(ខ) ដូចសំណួរ(ក)ដែរ បើយើងប្តូរពីទឹកមកបារ៉ាតវិញដែលម៉ាសមាឌ $\rho_{\text{Hg}} = 13546\,\text{kg/m}^3$នៅ $20℃$ តើបារ៉ាតលូតបានកម្ពស់ប៉ុន្មាន?ចូរបង្ហាញការគណនារបស់អ្នក។

………………………………………………………………………………………………

………………………………………………………………………………………………

………………………………………………………………………………………………

……………………………………………………………………………………………។

## ៥.៥.២ សន្លឹកកិច្ចការពិសោធន៍វាស់វែង (ពិសោធន៍ស្រាវជ្រាវ)

យើងនឹងសិក្សាសន្លឹកកិច្ចការពិសោធន៍ស្រាវជ្រាវនៅផ្នែកនេះ។ ខាងក្រោមនេះជាគំរូមួយនៃសន្លឹកកិច្ចការ។

នៅពេលអ្នកសរសេរសន្លឹកកិច្ចការ អ្នកត្រូវគិតអំពី ៖

១. វត្ថុបំណង

២. ទ្រឹស្តី

៣. សំណួរ (ទាក់ទងនឹងទ្រឹស្តី និងការពិសោធន៍)

៤. តម្រូវការសម្ភារឧបទេស

៥. ដំណើរការ (ដំឡើង និងពិសោធ)

៦. លទ្ធផល

៧. សន្និដ្ឋាន

៨.ពិភាក្សា

ឧទាហរណ៍ គំរូសន្លឹកកិច្ចការពិសោធន៍ស្រាវជ្រាវ

### រង្វាស់រេស៊ីស្តង់អគ្គិសនី និងច្បាប់អូម

**១.វត្ថុបំណង ៖**

- កំណត់តម្លៃរេស៊ីស្តង់របស់រេស៊ីស្តរតាមរយៈកូដពណ៌ (Color codes) និងវាស់តម្លៃរបស់វាដោយប្រើ អូមម៉ែត្រ ទ្រនិច ឬអូមម៉ែត្រលេខ
- វាស់តង់ស្យុងនិងចរន្តអគ្គិសនីដូច្នេះយើងអាចកំណត់តម្លៃរេស៊ីស្តង់(មេគុណប្រាប់ទិសនៃបន្ទាត់)តាមក្រាប
- គណនាកម្រិតល្អៀងនៃរេស៊ីស្តង់
- កំណត់រេស៊ីស្តង់សមមូលក្នុងបង្គុំជាសេរី និងជាខ្នែង។

**២. ទ្រឹស្តី**

- រេស៊ីស្តង់មានន័យថា ទប់ ឬប្រឆាំង។ រេស៊ីស្តង់អគ្គិសនីមានន័យថាជាការប្រឆាំង ឬទប់លំហូរអេឡិចត្រុង ដែលហូរឆ្លងកាត់ខ្សែចម្លង ឬអង្គធាតុចម្លង។

កូដពណ៌របស់រេស៊ីស្តរ (Resistor color code)

| ខ្សែវង់ ឬកងពីរដំបូង (First two Bands) | | ខ្សែវង់ ឬកងទីបី(Third Band) | | ខ្សែវង់ ឬកងទីបួន (Fourth Band) |
|---|---|---|---|---|
| ពណ៌ (Colors) | លេខ (Digits) | ពណ៌ (Color) | ស្វ័យគុណ (Exponent) | ពណ៌ (Color) |
| ខ្មៅ (Black) | 0 | Black | 0 | Colorless |
| ត្នោត (Brown) | 1 | Brown | 1 | 1% |
| ក្រហម (Red) | 2 | Red | 2 | 2% |
| ទឹកក្រូច(Orange) | 3 | Orange | 3 | 3% |
| លឿង (Yellow) | 4 | Yellow | 4 | 4% |
| បៃតង (Green) | 5 | Green | 5 | Gold 5% |
| ខៀវ (Blue) | 6 | Blue | 6 | Silver 10% |
| ស្វាយ (Violet) | 7 | Violet | 7 | |
| ប្រផេះ (Gray) | 8 | Silver | -2 | |

| | | | | |
|---|---|---|---|---|
| ស (White) | 9 | Gold | -1 | |

➢ រេស៊ីស្តង់បំព្រួញ

560R មានន័យថា 560 Ω

2K5 មានន័យថា 2.5K = 2 500 Ω

45K មានន័យថា 45K = 45 000 Ω

2MO មានន័យថា 2.0M = 2000K = 2 000 000 Ω

រេស៊ីស្តរ និងរេស៊ីស្តង់ | និមិត្តសញ្ញារបស់វា





➢ រេស៊ីស្តរអានុភាពខ្ពស់ (High power resistor)

ថាមពលអគ្គិសនីត្រូវបានបំប្លែងទៅជាកម្តៅ កាលណាចរន្តឆ្លងកាត់រេស៊ីស្តរ។ ខាងក្រោមនេះជារេស៊ីស្តរអានុភាពខ្ពស់ ដែលមានរេស៊ីស្តង់ 22 Ω និងអានុភាព 15W។




➢ រេស៊ីស្តង់នៃអង្គធាតុចម្លងឱ្យតាមរូបមន្ត ៖ $R = \rho L / A$ (1)

ដែល $R$ គិតជា (Ω), $L$ គិតជា (m), និង $A$ គិតជា ($m^2$)។ ជាធម្មតា $R$ អាស្រ័យនឹងសីតុណ្ហភាព ដូចដែលយើងបានសិក្សាក្នុងពិសោធន៍មុន។ កាលណាតង់ស្យុងត្រូវបានអនុវត្តរវាងគោលទាំងពីនៃរេស៊ីស្តរ នោះមានលំហូរចរន្តឆ្លងកាត់រេស៊ីស្តរ។ រូបមន្តរបស់វាឱ្យដោយ ៖ $R = V / I$ (2)

ដែល $R$ គិតជា (Ω), $V$ គិតជា (V), និង $I$ គិតជា (A)។

➢ បង្គុំរេស៊ីស្តង់ជាស៊េរី

រេស៊ីស្តង់សមមូល R ៖ $R = R_1 + R_2 + R_3$ (3)




➢ បង្គុំរេស៊ីស្តង់ជាខ្នែង

រេស៊ីស្តង់សមមូល R ៖ $1/R = 1/R_1 + 1/R_2 + 1/R_3$ (3)




ឧទាហរណ៍ ៖ គេឱ្យរេស៊ីស្តរមួយដែលមានពណ៌ក្រហម-ក្រហម-ខ្មៅ-ទឹកមាស។ តើមានន័យដូចម្តេចចំពោះរេស៊ីស្តរនេះ។ ដោយប្រើអូមម៉ែត្រ ចូរវាស់តម្លៃនៃរេស៊ីស្តង់នេះ។ តើកម្រិតល្អៀងមានតម្លៃប៉ុន្មាន?

ដំណោះស្រាយ

- កូដពណ៌នៃរេស៊ីស្តរនេះបង្ហាញថាតម្លៃរេស៊ីស្តង់គឺ22 Ω ± 5%តម្លៃរបស់វាស្ថិតនៅចន្លោះប្រហែល ពី21~23 Ω។
- ដោយប្រើអូមម៉ែត្រ តម្លៃនៃរេស៊ីស្តង់នេះគឺ 21.9 Ω ។
- កម្រិតល្អៀងមានតម្លៃ %Error = $|R_{theo} - R_{exp}|$×100% / $R_{theo}$ = 0.45 % ។

## ៣. សំណួរមុនពេលធ្វើពិសោធន

១. ដូចម្តេចដែលហៅថារេស៊ីស្តង់ ? រេស៊ីស្តង់នៃអង្គធាតុចម្លងអូម ?

២. គេឱ្យរេស៊ីសស្តរមួយដែលមានពណ៌ ក្រហម-ក្រហម-ក្រហម-ទឹកមាស។ ចូរអានពណ៌ដើម្បីរកតម្លៃរេស៊ីស្តង់របស់រេស៊ីស្តរនេះ។ ដោយប្រើអូមម៉ែត្ររេស៊ីស្តង់របស់វាមានតម្លៃ 2085Ω។ តើកម្រិតល្អៀងរបស់វាមានតម្លៃប៉ុន្មាន?

៣.មានរេស៊ីស្តរពីរដែលរេស៊ីស្តង់ទីគេ ១គឺ $R_1$ = 22 Ω និង $R_2$ = 33 Ω ។ គេតវាជាស៊េរី តើរេស៊ីស្តង់សមមូល របស់វាមានតម្លៃប៉ុន្មាន ?បើគេតវាជាខ្នែង តើរេស៊ីស្តង់សមមូលរបស់វាមានតម្លៃប៉ុន្មាន ?

៤.គេមានរេស៊ីស្តរ3 ដែលរេស៊ីស្តង់ទី ១គឺ $R_1$ = 22 Ω , $R_2$ = 33 Ω និង $R_3$ = 11 Ω ។ តើរេស៊ីស្តង់សមមូលរបស់វា មានតម្លៃប៉ុន្មានបើគេតវា ៖ ?

ក .$R_1$, $R_2$, និង $R_3$ ជាស៊េរី ។

ខ .$R_1$, $R_3$ ជាស៊េរី និង $R_2$ ជាខ្នែង ។

៥. គេមានរេស៊ីស្តរបីដែលរេស៊ីស្តង់ $R_1$ = 22 Ω , $R_2$ = 33 Ω និង $R_3$ = 11 Ω ។ តើចរន្តឆ្លងកាត់រេស៊ីស្តង់នីមួយៗមានតម្លៃប៉ុន្មាន? បើគេភ្ជាប់វាទៅនឹងប្រភព9.0 V និងតវាក្នុងករណី ៖

ក .$R_1$, $R_2$, និង $R_3$ ជាស៊េរី ។

ខ .$R_1$, $R_3$ ជាស៊េរី និង $R_2$ ជាខ្នែង ។

៦.គេមានរេស៊ីស្តរពីរដែលរេស៊ីស្តង់ $R_1$ = 50 Ω , $R_2$ = 25 Ω ។ តើរេស៊ីស្តរណាមួយក្តៅជាង បើគេភ្ជាប់វាទៅនឹងប្រភព 9.0 V និងតវាក្នុងករណី៖

ក .$R_1$ និង $R_2$ ជាស៊េរី ។

ខ .$R_1$ និង $R_2$ ជាខ្នែង។

## ៤. តម្រូវការសម្ភារៈ

- ប្រអប់រេស៊ីស្តង់ (1000 Ω) (ដែលមានរេស៊ីស្តង់ 50.0 Ω, 70.0 Ω, 90.0 Ω, 120.0 Ω, 150.0 Ω)
- អំពែម៉ែត្រចរន្តជាប់ (0-400 mA)
- តង់ស្យុងចរន្តជាប់ (0-22 V)
- ប្រភពចរន្តជាប់ (0-22 V at 0.50 A) ។

## ៥. ដំណើរការពិសោធ

ក. ភ្ជាប់អំពែម៉ែត្រ វ៉ុលម៉ែត្រ និងប្រភព PS ទៅនឹងរេស៊ីស្តរ។ សៀគ្វីគោល រួមមានប្រភពតជាស៊េរីជាមួយនឹងរេស៊ីស្តរមួយ។ ដើម្បីវាស់ចរន្តអគ្គិសនីឆ្លងកាត់រេស៊ីស្តរ គេត្រូវតអំពែម៉ែត្រជាស៊េរីជាមួយនឹងរេស៊ីស្តរ។ ប៉ុន្តែដើម្បីវាស់តង់ស្យុងឆ្លងកាត់រេស៊ីស្តរ គេត្រូវតវ៉ុលម៉ែត្រជាខ្នែងជាមួយនឹងរេស៊ីស្តរ។

ខ. ធ្វើបម្រែបម្រួលចរន្តឆ្លងកាត់រេស៊ីស្តរ $R_1$ មួយជំហានៗមានតម្លៃប្រហែល 30.0 mA (មើលតារាងទិន្នន័យទី១) ។ចំពោះតម្លៃជាក់លាក់នៃចរន្តនីមួយៗ ចូរវាស់តង់ស្យុងឆ្លងកាត់រេស៊ីស្តរ និងកត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី១។ រេស៊ីស្តរនឹងឡើងក្តៅ ហើយខូចបើចរន្តឆ្លងកាត់វាយូរពេក។ ការវាស់គួរតែធ្វើឱ្យបានឆាប់តាមដែលអាចធ្វើទៅបានចំពោះតម្លៃនីមួយៗនៃចរន្ត។ ចូរភ្ជាប់តង់ស្យុងតែនៅពេលដែលយើងវាស់យកទិន្នន័យរបស់វាប៉ុណ្ណោះ។

គ. ធ្វើចំណុច ខ ឡើងវិញនូវរាល់តម្លៃនីមួយៗនៃរេស៊ីស្តរទាំង៥។ រាល់តម្លៃនីមួយៗនៃរេស៊ីស្តរ អំពែម៉េត្រត្រូវតជាសេរីជាមួយនិងរេស៊ីស្តរ និងប្រភព ហើយវ៉ុលម៉ែត្រត្រូវតជាខ្នែងជាមួយនិងរេស៊ីស្តរ។ កត់ត្រាទិន្នន័យទាំងអស់ដាក់ក្នុង តារាងទិន្នន័យទី១។

ឃ.តរេស៊ីស្តរបីដំបូងជាសេរី រួចវាស់រេស៊ីស្តង់សមមូលរបស់វា ប្រើតម្លៃពីរនៃចរន្តគឺ 50.0 mA និង 75.0 mA (មើលតារាទិន្នន័យទី២) និងវាស់តង់ស្យុងដែលត្រូវគ្នា និងតម្លៃនីមួៗដែលត្រូវគ្នានិងចរន្តនេះ។ កត់ត្រាតម្លៃតង់ស្យុងដាក់ក្នុង តារាងទិន្នន័យទី២។

ង. វាស់តង់ស្យុងឆ្លងកាត់បង្គុំ $R_1$, $R_2$ និង $R_3$ ដែលតជាស៊េរីដែលមានចរន្ត 50.0 mA និង 75.0 mA កត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី២។ ដំណើរការដូចគ្នាចំពោះ $R_1$ និង $R_2$ ដែលតជាស៊េរី។

ច. ត$R_1$ និង $R_2$ ជាខ្នែង វាស់តង់ស្យុងឆ្លងកាត់បង្គុំដោយឱ្យចរន្ត 50.0 mA និង 75.0 mA ឆ្លងកាត់។ កត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី២។

ឆ. ត$R_1$ និង $R_2$ ជាខ្នែង វាស់តង់ស្យុងឆ្លងកាត់បង្គុំដោយឱ្យចរន្ត 50.0 mA និង 75.0 mA ឆ្លងកាត់។ កត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី២។

ជ. ត$R_2$ និង $R_3$ ជាខ្នែង និងវាស់តង់ស្យុងឆ្លងកាត់បង្គុំដោយឱ្យចរន្ត 50.0 mA និង 75.0 mA ឆ្លងកាត់។ កត់ត្រាតម្លៃរបស់វាដាក់ក្នុងតារាងទិន្នន័យទី២។

- ដំបូន្មានសម្រាប់ការគណនា

១. ពិសោធន៍នេះអ្នកប្រើរេស៊ីស្តរពិត ដូច្នេះអ្នកអាវអានកូដពណ៌ដើម្បីកំណត់រេស៊ីស្តង់ ឬប្រើអូមម៉ែត្រដើម្បីវាស់តម្លៃរបស់វាក៏បានដែរ។ កត់ត្រាតម្លៃរេស៊ីស្តង់ដាក់ក្នុងលទ្ធផលទី១ នេះជាតម្លៃទ្រឹស្តី$R_{theo}$។

២. បើសមីការត្រូវបានប្រើដើម្បីទាញរក នោះលទ្ធផលគឺ $V=RI$។ មានទំនាក់ទំនងបើនៃអ៊ែររវាងតង់ស្យុង $V$និងចរន្ត $I$មេគុណប្រាប់ទិសនៃបន្ទាត់គឺ R ។ គូរក្រាប $V$ជាអនុគមន៍នៃ $I$ដោយប្រើទិន្នន័យក្នុងតារាងទិន្នន័យទី១ដោយ $V$ ស្ថិតលើអ័ក្សឈរ និង $I$ ស្ថិតលើអ័ក្សដេក។ កត់ត្រាមេគុណប្រាប់ទិសក្នុងតារាងគណនាទី១ នេះជាតម្លៃតាមពិសោធន៍($R_{exp}$)។ កត់ត្រាមេគុណទំនាក់ទំនង $r$ (correlation coefficient) នៃក្រាប។

៣. គណនាកម្រិតល្អៀងនៃតម្លៃ $R_{exp}$ ដោយធៀបនឹងតម្លៃតាមទ្រឹស្តី $R_{theo}$ សម្រាប់រេស៊ីស្តរទាំងប្រាំ និងកត់ត្រាលទ្ធផលដាក់ក្នុងតារាងគណនាទី១។

៤. ចំពោះទិន្នន័យនៃតារាងទិន្នន័យទី២ គណនារេស៊ីស្តង់សមមូលក្នុងបង្គុំជាសេរី និងជាខ្នែងដែលកត់ត្រាក្នុងតារាងជាផលធៀបតម្លៃរវាងតង់ស្យុង និងចរន្ត។ គណនា និងកត់ត្រាតម្លៃមធ្យម( $R_{e(exp)}$ )ចូលក្នុងតារាងគណនាទី២។

៥. សមីការ 3 និង4 ជាកន្សោមតាមទ្រឹស្តីនៃរេស៊ីស្តង់សមមូលក្នុងបង្គុំជាស៊េរី និងជាខ្នែង។ គណនាតម្លៃរេស៊ីស្តង់សមមូលតាមទ្រឹស្តីក្នុងបង្គុំជាស៊េរី និងជាខ្នែងដែលវាស់ក្នុងតារាងទិន្នន័យទី២។ វាស់ ឬអានកូដពណ៌នៃរេស៊ីស្តង់ $R_1$, $R_2$ និង $R_3$ ។ កត់ត្រាតម្លៃរេស៊ីស្តង់សមមូលនីមួយៗតាមទ្រឹស្តី ($R_{e(the)}$)ដាក់ក្នុងតារាងទិន្នន័យទី២។

៦. គណនា %ផលសងរវាងតម្លៃតាមពិសោធន៍( $R_{e(exp)}$ ) និងតម្លៃតាមទ្រឹស្តី( $R_{e(the)}$ ) ក្នុងបង្គុំជាស៊េរី និងជាខ្នែងនីមួយៗ និងកត់ត្រាលទ្ធផលដាក់ក្នុងតារាងគណនាទី២។




➢ ដំបូន្មានសម្រាប់ការគូរក្រាប

១.សង់ក្រាប V ជាអនុគមន៍នៃ I ( ដោយ V ស្ថិតលើអ័ក្សឈរ និង I ស្ថិតលើអ័ក្សដេក ) ដោយប្រើទិន្នន័យក្នុងតារាងទិន្នន័យទី១។ អ្នកអាចគូសក្រាបប្រាំលើក្រដាសគូសក្រាប ១សន្លឹក។

៦. របាយការណ៍ពិសាធន៍ ( LABORATORY REPORT )

តារាងទិន្នន័យទី១ ( Data Table 1 )

| $I$ ( mA ) | $V_{R1}$( V ) | $V_{R2}$( V ) | $V_{R3}$( V ) | $V_{R4}$( V ) | $V_{R5}$( V ) |
|---|---|---|---|---|---|
| 0 | | | | | |
| 30.0 | | | | | |
| 60.0 | | | | | |
| 90.0 | | | | | |
| 120.0 | | | | | |

តារាងគណនាទី១ ( Calculation Table 1 )

| | $R_1$ | $R_2$ | $R_3$ | $R_4$ | $R_5$ |
|---|---|---|---|---|---|
| $R_{theo}$( Ω ) | | | | | |
| $R_{exp}$( Ω ) | | | | | |
| $r$ ( មេគុណសមមាត្រ ) | | | | | |
| %Error $R_{exp}$ | | | | | |

ក្រាប



Voltage $V_{R1}$ (V)
Current $I$ (A)




Voltage $V_{R2}$ (V)
Current $I$ (A)




Voltage $V_{R3}$ (V)
Current $I$ (A)




Voltage $V_{R4}$ (V)
Current $I$ (A)




Voltage $V_{R5}$ (V)
Current $I$ (A)

តារាងទិន្នន័យទី២ (Data Table 2)

| បង្គុំ | $I$(mA) | $V$(V) | $I$(mA) | $V$(V) |
|---|---|---|---|---|
| $R_1$ $R_2$ $R_3$ ស៊េរី | 50.0 | | 75.0 | |
| $R_1$ $R_2$ ស៊េរី | 50.0 | | 75.0 | |
| $R_1$ $R_2$ ខ្នែង | 50.0 | | 75.0 | |
| $R_1$ $R_3$ ខ្នែង | 50.0 | | 75.0 | |
| $R_2$ $R_3$ ខ្នែង | 50.0 | | 75.0 | |

តារាងគណនាទី២ (Calculation Table 2)

| បង្គុំ | $(R_e)_{exp}1\ (\Omega)$ | $(R_e)_{exp}2\ (\Omega)$ | $(\bar{R}_e)_{exp}\ (\Omega)$ | $(R_e)_{theo}\ (\Omega)$ | %ផលសង |
|---|---|---|---|---|---|
| $R_1$ $R_2$ $R_3$ ស៊េរី | | | | | |
| $R_1$ $R_2$ ស៊េរី | | | | | |
| $R_1$ $R_2$ ខ្នែង | | | | | |
| $R_1$ $R_3$ ខ្នែង | | | | | |
| $R_2$ $R_3$ ខ្នែង | | | | | |

❖ ការគណនាគំរូ

$(R_e)_{exp} = V / I =$

$$\%\text{កម្រិតល្អៀង} = \left|\frac{\text{តម្លៃទ្រឹស្តី} - \text{តម្លៃពិសោធន៍}}{\text{តម្លៃទ្រឹស្តី}}\right| \times 100\% =$$

(ស៊េរី) $(R_e)_{theo} = R_1 + R_2 + R_3 =$

(ខ្នែង) $(R_e)_{theo} = 1 / (1/R_1 + 1/R_2) =$

$$\%\ \text{ផលសង} = \left|\frac{\text{តម្លៃវាស់តាមវិធីទី១} - \text{តម្លៃវាស់តាមវិធីទី២}}{(\text{តម្លៃវាស់តាមវិធីទី១} + \text{តម្លៃវាស់តាមវិធីទី២})/2}\right| \times 100\% =$$

## ៧.សន្និដ្ឋាន

ផ្អែកលើលទ្ធផលពិសោធន៍ខាងលើ %កម្រិតល្អៀងនៃរេស៊ីស្តង់ និង%ផលសងនៃរេស៊ីស្តង់……………… … និងមេគុណទំនាក់ទំនង r = …………………។

ដូចនេះ អ្នកអាចសន្និដ្ឋានថា តម្លៃរេស៊ីស្តង់អគ្គិសនី និងរេស៊ីស្តង់សមមូលក្នុងបង្គុំជាស៊េរី និងខ្នែងអាចត្រូវ……………………………… ហើយ ចរន្ត និងតង់ស្យុងអគ្គិសនីមាន………………………………………… ។

## ៨. ពិភាក្សា

(ក) តើមានកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើលទ្ធផលពិសោធន៍របស់អ្នកដែលអាចធ្វើឱ្យអ្នកមិនទទួលបានលទ្ធផលល្អ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

(ខ) តើអ្នកមានគំនិតកែលម្អពិសោធន៍នេះយ៉ាងដូចម្ដេច ដើម្បីឱ្យការធ្វើពិសោធន៍លើកក្រោយៗទៀតទទួលបានលទ្ធផលល្អប្រសើរជាងនេះ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

## ៥.៣ គំរូសន្លឹកកិច្ចការពិសោធន៍ស្រាវជ្រាវផ្សេងទៀត
## ពិសោធចំណាំងផ្លាតនៃពន្លឺ

### ១.វត្ថុបំណង

បង្ហាញថាមុំចំណាំងផ្លាតប៉ុនគ្នានឹងមុំចំណាំងប៉ះតាមរយៈការធ្វើពិសោធ។

### ២.តម្រូវការសម្ភារៈ

កញ្ចក់ប្លង់១ ម្ជុលបារាំង៥ដើម ស្កុត១ដុំ ក្រដាសកាតុងក្រាស់ ឬសំបកកេសមី១ផ្ទាំង បន្ទាត់ម៉ែត្រវែង១ ក្រដាសការ៉ូ ឬក្រដាសគូសក្រាប១សន្លឹក និងខ្មៅដៃ១ដើម។

### ៣.ដំណើរការពិសោធន៍

ក. ដាក់ក្រដាសគូសក្រាបលើក្រដាសកាតុងក្រាស ឬសំបកកេសដែលជាទម្រ។

ខ. ដោយប្រើស្កុត។(ក្រដាសកាតុងក្រាស) បិទក្រដាសគូរក្រាបភ្ជាប់នឹងទម្រ

គ. ដាក់កញ្ចក់ប្លង់លើក្រដាសគូរក្រាបត្រង់ពាក់កណ្ដាលក្រដាស។

ឃ. គូសបន្ទាត់មួយតាមបណ្ដោយកញ្ចក់ ដូចបង្ហាយក្នុងរូបខាងក្រោម។

ង. ដោតម្ជុលទី១នៅត្រង់ចំណុច មួយលើជ្រុងនៃកញ្ចក់ ដូចរូបខាងក្រោម។

ច.ដោតម្ជុលទី២នៅត្រង់ចំណុចមួយចម្ងាយប្រហែល2cmពីមុខកញ្ចក់។ ចំណុចនេះតាងដោយ $O_1$។ ដោតម្ជុលទី៣នៅត្រង់ចំណុច$O_2$ ដោយលៃតម្រង់ភ្នែក ចំណុច$O$, $O_1$ និង$O_2$រត់ត្រង់គ្នា។

ឆ. ដោតម្ជុលទី៤ត្រង់ចំណុច$R_1$ឱ្យរត់ត្រង់ជួរគ្នាជាមួយនឹងចំណុច$O$រូបភាពនៃ$O_1$ , និង $O_2$។ រូបភាពនៃ$O_1$ និង $O_2$គឺ $O'_1$ និង $O'_2$រៀងគ្នា បង្ហាញដូចរូបខាងក្រោម។

ជ. ធ្វើដូចចំណុច ឆ. ដោយដោតម្ជុលទី៥ត្រង់ចំណុច$R_2$។

ឈ. រក្សាម្ជុលទី១ ប៉ុន្តែដកម្ជុលទី២ ៣ ៤និង ៥ ចេញ រួចធ្វើតាមចំណុច ច ឆ ជ សារឡើងវិញ ២ឬ ៣ ដងថែមទៀត។

ញ. ដកកញ្ចក់ និងម្ជុលចេញពីក្រដាស

ដ. គូសកាំចាំងប៉ះ(ខ្សែ ឬបន្ទាត់ត្រង់) កាត់តាមរន្ធម្ជុលទី១ និងទី២ រួចគូសកាំចាំងផ្លាតកាត់តាមរន្ធម្ជុលទី៣ និងទី៤។

ឋ. គូសខ្សែ ឬបន្ទាត់ឱ្យកែងទៅនឹងខ្សែដែលគូសតាមបណ្ដោយកញ្ចក់ត្រង់ចំណុចប្រសព្វរវាងកាំចាំប៉ះនិងកាំចាំងផ្លាត។ ខ្សែនេះត្រូវបានគេហៅថា ខ្សែកែង។

ឌ. វាស់ប្រវែងពីកាំចាំងប៉ះទៅខ្សែកែង ប្រវែងនេះតាងដោយ $I_0$, ពីកាំចាំងផ្លាតទៅខ្សែកែងប្រវែងនេះតាងដោយ $I_1$ និងពីកញ្ចក់ទៅចំណុច $H$ ប្រវែងនេះតាងដោយ $I_2$។






### ៤.លទ្ធផល

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| $I_0$ (cm) | | | | | |
| $I_1$ (cm) | | | | | |
| $I_2$ (cm) | | | | | |
| $\tan i$ | | | | | |
| $\tan r$ | | | | | |
| $i$ ដឺក្រេ | | | | | |
| $r$ ដឺក្រេ | | | | | |

## ៥. សន្និដ្ឋាន

តាមលទ្ធផលខាងលើ យើងសង្កេតឃើញថាមុំ $i_1 \ldots\ldots r_1,\ i_2 \ldots\ldots r_2,\ i_3 \ldots\ldots r_3,$ និង $i_4 \ldots\ldots r_4$ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថាមុំចំណាំងប៉ះ $(i)$ ……………… មុំចំណាំងផ្លាត $(r)$។

## ៦. ពិភាក្សា

១.តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ការពិសោធន៍របស់អ្នកមិនទទួលបានលទ្ធផលល្អ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

២. ដើម្បីឱ្យការធ្វើពិសោធន៍លើកក្រោយៗទៀតទទួលបានលទ្ធផលល្អប្រសើរជាងនេះតើអ្នកមានគំនិតកែលម្អរដូចម្តេច?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

………………………………………………………………………………

## ៦. ការសរសេរសន្លឹកកិច្ចការពិសោធន៍

ការបង្រៀនពិសោធន៍ដោយគ្រូបង្គោល

**ប្រធានបទទី១៖ ប្រើវិធីវិទ្យាសាស្ត្រ**

**បង្គុំរេស៊ីស្តង់អគ្គិសនីជាស៊េរី**

- **វត្ថុបំណង**

បង្ហាញថាក្នុងបង្គុំរេស៊ីស្តង់ជាស៊េរី៖

- ចរន្តឆ្លងកាត់រេស៊ីស្តង់នីមួយៗមានតម្លៃស្មើៗគ្នា។
- តង់ស្យុងនៃប្រភពស្មើនឹងផលបូកតង់ស្យុងឆ្លងកាត់រេស៊ីស្តង់នីមួយៗ។
- រេស៊ីស្តង់សមមូលនៃបង្គុំស្មើនឹងផលបូករេស៊ីស្តង់នីមួយៗ។

### ១. ការកំណត់បញ្ហា

ក្នុងបង្គុំជាស៊េរី តើចរន្តអគ្គិសនីដែលឆ្លងកាត់រេស៊ីស្តង់នីមួយៗ តង់ស្យុងនៃប្រភព និងរេស៊ីស្តង់សមមូលនៃបង្គុំមានតម្លៃដូចម្តេច?

### ២. ការបង្កើតសម្មតិកម្ម៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

ហេតុអ្វីបានជាអ្នកគិតដូច្នេះ?

ព្រោះ៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

### ៣. តេស្តសម្មតិកម្ម (ពិសោធន៍)

(ក) តម្រូវការសម្ភារពិសោធន៍

- បន្ទះសៀគ្វី (Bread board)
- ខ្សែភ្លើងសម្រាប់ដោត
- បាតឺរី 12.0 V និងប្រដាប់ភ្ជាប់វា
- រេស៊ីស្តរ 3គ្រាប់ ($R_1 = 20\,\Omega, R_2 = 40\,\Omega,$និង$R_3 = 60\,\Omega,$)
- ម៉ុលទីម៉ែត្រ
- អំពែម៉ែត្រ និងអូមម៉ែត្រ។

(ខ) ដំណើរការពិសោធន៍

ដើម្បីសម្រួលក្នុងការធ្វើពិសោធ ខ្ញុំនឹងប្រើប្រាស់ការពិសោធតាម E-Lab និងជំឡើងវាដោយសង្ខេប។ ពិនិត្យសៀគ្វីដែលបង្ហាញដូចរូបខាងក្រោម៖




- ពិនិត្យមើលអំពែម៉ែត្រទី១ ទី២ ទី៣ និងទី៤ រួចស្រង់ទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។ អំពែម៉ែត្រតជាសេរីជាមួយនឹងរេស៊ីស្តង់។
- ពិនិត្យមើលវ៉ុលម៉ែត្រទី១ ទី២ ទី៣ និងទី៤ រួចស្រង់ទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។ វ៉ុលម៉ែត្រតជាខ្នែង។
- គណនារេស៊ីស្តង់សមមូលក្នុងបង្គុំជាសេរី ឬវាស់វាដោយប្រើអូមម៉ែត្រ។ រូបខាងក្រោមបង្ហាញពីការវាស់រេស៊ីស្តង់សមមូលតាមE-Lab។




## ៤. លទ្ធផល

តារាងទិន្នន័យ( រេស៊ីស្តង់ផ្គុំជាសេរី )

| រេស៊ីស្តង់(Ω) | អំពែម៉ែត្របង្ហាញ(A) | វ៉ុលម៉ែត្របង្ហាញ(V) |
|---|---|---|
| $R_1 = 20\,\Omega$ | | |
| $R_2 = 40\,\Omega$ | | |
| $R_3 = 60\Omega$ | | |
| ប្រភពអគ្គិសនី | | |
| រេស៊ីស្តង់សមមូល $R$ | | |

## ៥.សន្និដ្ឋាន

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

**ប្រធានបទទី២ ប្រើការបង្រៀនតាមបែបរិះរក( IBL )**

## បន្ទុំរេស៊ីស្តង់អគ្គិសនីជាខ្នែង

### វត្ថុបំណង

បង្ហាញថាក្នុងបង្គុំរេស៊ីស្តង់ជាខ្នែង៖

- តង់ស្យុងនៃប្រភពមានតម្លៃស្មើនឹងតង់ស្យុងឆ្លងកាត់រេស៊ីស្តង់ក្នុងខ្នែងនីមួយៗ។
- ចរន្តអគ្គិសនីសរុប( ផ្លូប )ស្មើនឹងផលបូកចរន្តអគ្គសនីឆ្លងកាត់រេស៊ីស្តង់ក្នុងខ្នែងនីមួយៗ។
- កំណត់រេស៊ីស្តង់សមមូលនៃបង្គុំ។

ការបង្ហាញបាតុភូត( ឬលំនាំបញ្ហា )




### ១. សំណួរគន្លឹះ

ក្នុងបង្គុំជាខ្នែង តើចរន្តអគ្គិសនីដែលឆ្លងកាត់រេស៊ីស្តង់នីមួយៗ តង់ស្យុងនៃប្រភព និងរេស៊ីស្តង់សមមូលនៃ បង្គុំមានតម្លៃដូចម្តេច?

### ២ .ការបង្កើតសម្មតិកម្ម៖

…………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………………………

…………………………………………………………………………………………………………………………………

### ៣. តេស្តសម្មតិកម្ម ( ពិសោធន៍ )

( ក )តម្រូវការសម្ភារពិសោធន៍

- បន្ទះសៀគ្វី ( Bread board )
- ខ្សែភ្លើងសម្រាប់ដោត
- បាតឺរី 12.0 V និងប្រដាប់ភ្ជាប់វា
- រេស៊ីស្តរ 3គ្រាប់ ( $R_1 = 20\ \Omega, R_2 = 40\ \Omega,$និង$R_3 = 60\ \Omega,$ )
- ម៉ុលទីម៉ែត្រ
- អំពែម៉ែត្រ និងអូមម៉ែត្រ។

( ខ ) ប្លង់ពិសោធន៍

……………………………………………………………………………………………………………………
……………………………………………………………………………………………………………………
……………………………………………………………………………………………………………………
……………………………………………………………………………………………………………………
……………………………………………………………………………………………………………………

## ដំណើរការពិសោធន៍

ដើម្បីសម្រួលក្នុងការធ្វើពិសោធ ខ្ញុំនឹងប្រើប្រាស់ការពិសោធតាមE-Lab និងដំឡើងវាដោយសង្ខេប។ ពិនិត្យសៀគ្វីដែលបង្ហាញដូចរូបខាងក្រោម៖




- ពិនិត្យមើលអំពែម៉ែត្រទី១ ទី២ ទី៣ និងទី៤ រួចស្រង់ទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។ អំពែម៉ែត្រតជាសេរីជាមួយនឹងរេស៊ីស្តង់។

- ពិនិត្យមើលវ៉ុលម៉ែត្រទី១ ទី២ ទី៣ និងទី៤ រួចស្រង់ទិន្នន័យដាក់ក្នុងតារាងទិន្នន័យខាងក្រោម។ វ៉ុលម៉ែត្រតជាខ្នែង។

-គណនារេស៊ីស្តង់សមមូលក្នុងបង្គុំជាសេរី ឬវាស់វាដោយប្រើអូមម៉ែត្រ។ រូបខាងក្រោមបង្ហាញពីការវាស់រេស៊ីស្តង់សមមូលតាមE-Lab។



## ៥. លទ្ធផល

តារាងទិន្នន័យ(រេស៊ីស្តង់ផ្គុំជាខ្សែង)

| រេស៊ីស្តង់(Ω) | អំពែម៉ែត្របង្ហាញ(A) | វ៉ុលម៉ែត្របង្ហាញ(V) |
|---|---|---|
| $R_1 = 20\ \Omega$ | | |
| $R_2 = 40\ \Omega$ | | |
| $R_3 = 60\Omega$ | | |
| ប្រភពអគ្គិសនី | | |
| រេស៊ីស្តង់សមមូល $R$ | | |

## ៦. សន្និដ្ឋានៈ

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

…………………………………………………………………………………………………………………

## ៧. វិធីសាស្ត្របង្រៀន និងរៀនពិសោធន៍

សម្រាប់ការបង្ហាញពិសោធន៍ទាំងពីរប្រធានបទ ខាងលើនេះគឺ

- ប្រធានបទទី១ ប្រើវិធីសាស្ត្រដែលមាន៥ជំហានៈ

  ១. ការកំណត់បញ្ហា

  ២. ការបង្កើតសម្មតិកម្ម

  ៣. ការធ្វើតេស្តសម្មតិកម្ម(ការធ្វើពិសោធ)

  ៤. លទ្ធផល

  ៥. ការវិភាគ និងសន្និដ្ឋាន

- ប្រធានបទទី២ ប្រើវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកដែលមានជំហានសំខាន់ៗដូចតទៅៈ

  ១. សំណួរគន្លឹះ

  ២. ការបង្កើតសម្មតិកម្ម

  ៣. ការធ្វើតេស្តសម្មតិកម្ម(ការធ្វើពិសោធ)

  ៤. លទ្ធផល

  ៥. សន្និដ្ឋាន

## ៨. សារប្រយោជន៍នៃសម្ភារឧបទេស

ចំពោះសម្ភារឧបទេសដែលបានប្រើដូចបង្ហាញខាងលើ ក្រៅពីបម្រើឱ្យការបង្រៀន និងរៀនក្នុងថ្នាក់ជាក់ស្តែង គេអាចប្រើវាក្នុងបច្ចេកទេស និងការរស់នៅរាល់ថ្ងៃផងដែរដូចជា ក្នុងសៀគ្វីអគ្គិសនី អេឡិចត្រូមេកានិច និងការតភ្លើងក្នុងផ្ទះ ភ្លើងលំអសួនច្បារ និងលំអពេលចូលឆ្នាំ ឬពិធីផ្សេងៗទៀត។...

# ឯកសារយោង


1. វិទ្យាស្ថានជាតិអប់រំ ឯកសារវិធីសាស្ត្របង្រៀនសម្រាប់ការបណ្តុះបណ្តាលគរុនិស្សិតឆ្នាំ ២០០០ - ២០០៥
2. ក្រសួងអប់រំ យុវជន និងកីឡា សៀវភៅសិក្សាគោលរូបវិទ្យា ថ្នាក់ទី ១០ បោះពុម្ពឆ្នាំ ២០២០
3. វិទ្យាស្ថានជាតិអប់រំ សៀវភៅពិសោធន៍វិទ្យាសាស្ត្រ ឆ្នាំ ២០០០ - ២០០៥
4. ទូច ចន្ទទុំ បូ ចាន់ថា សៀវភៅពិសោធន៍ប្រើប្រាស់សម្ភារក្នុងស្រុក ២០១០
5. ទូច ចន្ទទុំ E-Lap ឆ្នាំ ២០១៩